002/19-09-2007-ECCC/TC
E1/196

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 25 / 07 / 2013
ម៉ោង (Time/Heure) : 14:10
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier:

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

## <u>សាធារណៈ</u>

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បតិ៍ ទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣

### សវនាការលើអង្គសេចក្តី - ថ្ងៃទី ១៨៣

### រៀបចំដោយ៖ សែ កុលវុឌ្ឍី និង Roger PHILLIPS

| <u>កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ</u> |
| --- |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក វេង ហ៊ត, លោក Tarik ABDULHAK |
| ជនជាប់ចោទ៖ ខៀវ សំផន និង នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ) |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, |

| |
|---|
| លោកស្រី ទី ស្រីនណា, លោក Madhev MOHAN, លោក Pascal AUBOIN |
| ដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ថៅ នី (TCCP-187) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោកស្រី សួ សុទ្ធាវី, លោក អ៊ុច អារុណ |
| ផ្សេងៗ៖ |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ | ចាប់ផ្តើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១១.០៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ គ្មាន | បញ្ចប់ម៉ោង៖ គ្មាន |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ គ្មាន | បញ្ចប់ម៉ោង៖ គ្មាន |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៥.០៧ | បញ្ចប់ម៉ោង៖ ១៥.៣០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០២ ម៉ោង និង ០៥ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការលះបង់សិទ្ធិមានវត្តមានរបស់ជនជាប់ចោទក្នុងការចូលរួមដំណើរការសវនាការពីបន្ទប់សវនាការ | អង្គជំនុំជម្រះ | ០៩.១០ | ០៩.១០ |
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ថៅ នី (TCCP-187) | មេធាវីការពារក្តី ខៀវ សំផន | ០៩.១២ | ០៩.៣៨ |
| | ដើមបណ្តឹងរដ្ឋប្បវេណី | ០៩.៤០ | ០៩.៤១ |
| | | ០៩.៤៩ | ០៩.៥០ |
| | ជនជាប់ចោទ ខៀវ សំផន | ០៩.៤៣ | ០៩.៤៩ |
| | សហព្រះរាជអាជ្ញា | ០៩.៥១ | ១០.០៥ |
| | មេធាវីនាំមុខ ដ.ប.រ | ១០.០៦ | ១០.២៥ |
| សេចក្តីថ្លែងអំពីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី ថៅ នី | ដើមបណ្តឹងរដ្ឋប្បវេណី | ១០.២៧ | ១០.៣២ |
| ការកត់សម្គាល់អំពីសិទ្ធិក្នុងការតាំងសំណួរទៅជនជាប់ចោទ និងសិទ្ធិនៅស្ងៀមមិនឆ្លើយតប | សហព្រះរាជអាជ្ញា | ១០.៣២ | ១០.៣៥ |
| | មេធាវីនាំមុខ | ១០.៣៥ | ១០.៣៩ |

| | អង្គជំនុំជម្រះ | ១១.០១ | ១១.០២ |
|---|---|---|---|

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការលះបង់សិទ្ធិមានវត្តមានក្នុងកិច្ចដំណើរការសវនាការពីបន្ទប់សវនាការ**

ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនដែលនៅពីក្រោមសាលសវនាការនេះតាមវិធាន ៨១.៥ និង ផ្អែកតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើបញ្ហាសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣ (ឯកសារ E256/5) ។

**ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី (TCCP-187)**

ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី ត្រូវបានអង្គជំនុំជម្រះកោះហៅមកសាជាថ្មីតាមសំណើសុំរបស់មេធាវីការពារក្តី ខៀវ សំផន (E267/3)។ មេធាវីការពារក្តី ខៀវ សំផនបានតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី និងបន្តបន្ទាប់មកទៀត មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា បានតាំងសំណួរ និងបញ្ចប់ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី។ ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី បានតាំងសំណួរមួយចំនួនទៅជនជាប់ចោទ ខៀវ សំផន ដែលជនជាប់ចោទបានធ្វើការឆ្លើយតប។

**សេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី**

ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីថ្លែងទុក្ខសោក និងព្យសនកម្មដែលបានកើតមានចំពោះដើមបណ្តឹងផ្ទាល់។

**សិទ្ធិក្នុងការតាំងសំណួរទៅជនជាប់ចោទ និងសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ ជនជាប់ចោទ**

សហព្រះរាជអាជ្ញា និងមេធាវីនាំមុខបានធ្វើសេចក្តីសន្និដ្ឋានទាក់ទងនឹងសិទ្ធិក្នុងការតាំងសំណួរទៅជនជាប់ចោទអនុលោមតាមវិធាន ៩០។ អង្គជំនុំជម្រះបានស្នើឱ្យជនជាប់ចោទជូនដំណឹងមកអង្គជំនុំជម្រះវិញនៅថ្ងៃចន្ទ ទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ វេលាម៉ោង ៩ ព្រឹកវិញថាតើខ្លួនបំណងឆ្លើយតបទៅនឹងសំណួរនានាដែលសួរដោយភាគី និង អង្គជំនុំជម្រះដែរឬទេ ឬមួយប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| N/A | E1/146.1 | 00865447-00865537<br>00866675-00866783<br>00866563-00866674 | ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ - ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០១២<br>Transcript of hearing on the substance in Case 002 – 23 November 2012<br>Transcript of hearing on the substance in Case 002 – 23 November 2012 | P | | | | |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- បង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនដើមបណ្តឹង ថៅ នី ត្រឡប់ទៅកាន់គេហដ្ឋានរបស់គាត់វិញដោយសារសក្ខីកម្មរបស់គាត់បានបញ្ចប់។
- អង្គជំនុំជម្រះបានជូនដំណឹងថានៅសប្តាហ៍ឆាប់ៗខាងមុខនេះនឹងមានកិច្ចប្រជុំរៀបចំសវនាការ ដែលនៅពេលនោះជនជាប់ចោទ ខៀវ សំផន និង នួន ជា ត្រូវជូនដំណឹងមកអង្គជំនុំជម្រះវិញថាតើពួកគេត្រៀមខ្លួនរួចហើយឬនៅក្នុងការឆ្លើយសំណួរ ឬមួយប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ និងបង្គាប់ឲ្យនាំជនជាប់ចោទ ខៀវ សំផន មកកាន់សាលសវនាការវិញ និងជនជាប់ចោទ នួន ជា មកកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ ឲ្យបានមុនម៉ោង ០៩.០០ នាទី ព្រឹក ។

**កាលបរិច្ឆេទបន្តសវនាការ៖**

សវនាការនឹងបន្តនៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ វេលាម៉ោង ០៩ ព្រឹក។

ភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣

ក្រឡាបញ្ជី

សែ [illegible] Roger PHILLIPS